ថ្ងៃទី...01...2009
ចុះបញ្ជីលេខ....020

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ២៤០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ទិវាឆ្មបជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី.
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៦ / ៣៨៩ ចុះថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០០៦ ស្តីពី ការបង្កើតគណៈឆ្មបកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

## ស ម្រេ ច

**មាត្រា ១.-**

ត្រូវបានអនុញ្ញាតឱ្យឆ្មបនៃព្រះរាជាណាចក្រកម្ពុជាទាំងអស់ប្រារព្ធទិវានៅថ្ងៃ ០៥ ខែ ឧសភា រៀងរាល់ឆ្នាំ ឱ្យស្របតាម ទិវាឆ្មបអន្តរជាតិ ។

មាត្រា ២.-

មិវាផ្ទបជាតិត្រូវបានប្រារព្ធឡើងដើម្បី :

- រំលឹកគុណផ្ទបដែលបានបង្កើតទារក និងថែទាំសុខភាពមាតា ទារក
- បញ្ជាក់ថាផ្ទបជាភ្នាក់ងារដ៏សំខាន់នៃសេវាសុខភាព
- ពង្រឹង និងពង្រីកបណ្តាញផ្ទប និងសមត្ថភាពផ្ទប ដោយសហការយ៉ាងជិតស្និទ្ធជាមួយសហព័ន្ធផ្ទបអន្តរជាតិ
- បង្កើនទំនាក់ទំនងរវាងមន្ត្រីក្រសួងសុខាភិបាលគ្រប់ជាន់ថ្នាក់ និងដៃគូអភិវឌ្ឍន៍ ដែលមានទិសដៅដូចគ្នាក្នុងការថែទាំសុខភាពមាតា និងទារក
- បង្ហាញពីសារៈសំខាន់នៃវិជ្ជាជីវៈរបស់ផ្ទប ។

មាត្រា ៣.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ៨ ឆ្នាំ ២០០៨

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៤*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*